ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

# សៀវភៅណែនាំ
# ស្តីពី
# ភារកិច្ច និងភាតព្វកិច្ចរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

# សាររបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**លោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ជាទីស្រឡាញ់រាប់អាន !**

គ.ជ.ប មានជំនឿយ៉ាងមុតមាំថា នៅពេលជនគ្រប់រូបដែលពាក់ព័ន្ធនឹងការបោះឆ្នោតយល់ដឹងច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន អ្នកទាំងនោះនឹងចូលរួមចំណែកបានកាន់តែប្រសើរឡើង ធ្វើឱ្យការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌មួយសម្រេចបានជោគជ័យ។

លោក លោកស្រី ជាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មានតួនាទីសំខាន់ក្នុងការផ្តល់ព័ត៌មាន និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួនឱ្យចូលរួមក្នុងគ្រប់ទិដ្ឋភាពនៃដំណើរការបោះឆ្នោត។ លោក លោកស្រីស្ថិតក្នុងស្ថានភាពតែមួយ ក្នុងការបង្កើតបរិយាកាសជឿទុកចិត្តគ្នា អធ្យាស្រ័យគ្នា និងគោរពសិទ្ធិសេរីភាពបុគ្គល ដែលជាកត្តាចម្បងសម្រាប់ធ្វើឱ្យការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ទទួលបានជោគជ័យ។

សៀវភៅនេះមានគោលបំណងផ្តល់ជូននូវកម្រងវិធាន ភារកិច្ច និងកាតព្វកិច្ចនានា មានលក្ខណៈច្បាស់លាស់ ងាយយល់ ដែលលោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិអាចអនុវត្តបាន។ កម្រងវិធាន ភារកិច្ច និងកាតព្វកិច្ចទាំងនេះពិតជាមិនគ្រាន់តែអនុវត្តក្នុងដំណាក់កាលបោះឆ្នោតប៉ុណ្ណោះទេ ថែមទាំងត្រូវយកមកអនុវត្តក្នុងរាល់សកម្មភាពពាក់ព័ន្ធនឹងដំណើរការបោះឆ្នោតផ្សេងទៀត ដូចជាការផ្តល់ព័ត៌មានស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងការទទួលខុសត្រូវផ្សេងទៀតក្រៅអំឡុងពេលបោះឆ្នោត។

និយាយដោយសង្ខេប លោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ គឺជាអ្នករស់នៅជាប់នឹងប្រជាពលរដ្ឋ ម្ល៉ោះហើយ លោក លោកស្រីបានស្គាល់ច្បាស់ពីជីវភាពរបស់ប្រជាពលរដ្ឋ។

ជាការពិត ដើម្បីលើកមុខមាត់របស់លោក លោកស្រីជាសមាសភាពអព្យាក្រឹតមួយនៃរដ្ឋបាលសាធារណៈ ខ្ញុំយល់ថាជានិច្ចកាល លោក លោកស្រី ត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ចំពោះភារកិច្ច និងកាតព្វកិច្ច ដូចមានចែងក្នុងសៀវភៅនេះ។

ដូចនេះខ្ញុំសង្ឃឹមថា លោក លោកស្រី យកចិត្តទុកដាក់ ដោយចាត់ទុកថា សៀវភៅណែនាំនេះជាជំនួយស្មារតីដ៏មានតម្លៃសម្រាប់គ្រប់គ្រង នៅពេលបំពេញភារកិច្ចឱ្យបានជោគជ័យ និងជួយគាំទ្រដល់ដំណើរការរៀបចំការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។

ខ្ញុំសូមអរគុណចំពោះការចូលរួមសហការរបស់លោក លោកស្រី។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**

# មាតិកា

ទំព័រ

សេចក្តីផ្តើម ........................................................................ ១
ភាពអព្យាក្រឹត ........................................................................ ៣
ចៀសវាងការគំរាមកំហែង ........................................................................ ៥
សហការជាមួយនឹងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ........................................................................ ៨

# សេចក្ដីផ្ដើម

ភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិដែលបញ្ចូលក្នុងសៀវភៅនេះ យោងតាម ៖

- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- អនុក្រឹត្យលេខ ២២ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី និង ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្ដីណែនាំលេខ ០០៤ សណន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៦ របស់ក្រសួងមហាផ្ទៃ ស្ដីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្ដូរមេភូមិ ការតែងតាំងជំនួយការ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់មេភូមិ
- សេចក្ដីណែនាំរួមលេខ ០០២ ស.ណ.ន ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្ដីពីការធានានិរន្តរភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- សេចក្ដីសម្រេចលេខ ០៧៦ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការផលិត និងការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត
- អំណាចជាទូទៅដែលត្រូវបានប្រគល់ជូន គ.ជ.ប ក្នុងការចាត់គ្រប់វិធានការសមស្របដើម្បីធានានូវការបោះឆ្នោតមួយដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដូចមានចែងក្នុងច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់បោះឆ្នោត។

សៀវភៅណែនាំនេះជម្រាបជូននូវឥរិយាបថអនុវត្តការងារសំខាន់ៗ ៣ គឺ ៖

១- ជំហរអព្យាក្រឹត ឥតលម្អៀង

២- ចៀសវាងការគំរាមកំហែង

៣- សហការជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។




មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបម្រើអ្នកភូមិគ្រប់គ្នាដោយពុំប្រកាន់និន្នាការ
នយោបាយ និងពុំត្រូវបញ្ចេញទស្សនៈនយោបាយផ្ទាល់ខ្លួនទៅលើអ្នកភូមិ

# I-ភាពអព្យាក្រឹត

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មានកាតព្វកិច្ចបម្រើអ្នកភូមិគ្រប់ៗគ្នាដោយប្រកាន់ជំហរអព្យាក្រឹត ឥតលម្អៀងក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចដែលមានចែងក្នុងច្បាប់ ។

**ហាម !　　ហាម !　　ហាម !**

១. ហាមបង្ហាញជាចំហនូវគណបក្សនយោបាយរបស់ខ្លួន ឬ បង្ហាញការគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយជាសាធារណៈ។

២. ហាមប្រើប្រាស់សមត្ថកិច្ច និងឋានៈរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬព្យាយាមប្រើឥទ្ធិពលទៅលើអ្នកភូមិ។

៣. ហាមជ្រៀតជ្រែកទៅក្នុងទស្សនៈរបស់បុគ្គល ឬទៅក្នុងការជ្រើសរើសគណបក្សរបស់ប្រជាពលរដ្ឋក្នុងភូមិ ទោះជាតាមរូបភាពណាមួយក៏ដោយ។

៤. ហាមប្រើប្រាស់ឋានៈរបស់ខ្លួន ដើម្បីព្យាយាមដាក់ជម្រើសនយោបាយ ទៅលើអ្នកភូមិណាម្នាក់ ពីព្រោះក្នុងលទ្ធិប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការបញ្ចេញទស្សនៈផ្ទាល់ខ្លួន ដោយគ្មានការគាបសង្កត់ពីអាជ្ញាធរ។ គ្មានជនណាម្នាក់ត្រូវបានសមត្ថកិច្ចមូលដ្ឋានដាក់ទោសដោយសារជម្រើសជំនឿនយោបាយឡើយ។

៥. ហាមផ្អិបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មាន ដល់អ្នកភូមិទាំងឡាយ ដោយមានការរើសអើង ផ្អែកទៅលើគណបក្សដែលអ្នកភូមិគាំទ្រនោះឡើយ។ ឧទាហរណ៍៖ ការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត គឺជាភារកិច្ចផ្លូវការ ដែលមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិត្រូវតែព្យាយាមចែកជូនឱ្យបានដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតគ្រប់រូបក្នុងភូមិដោយមិនរើសមុខ។

**ត្រូវព្យាយាមធ្វើឱ្យបាន ៖**

១. ផ្តល់សេវា និងព័ត៌មាន ដូចៗគ្នា ដល់អ្នកភូមិគ្រប់ៗគ្នា ដោយមិនប្រកាន់និន្នាការនយោបាយរបស់អ្នកភូមិណាម្នាក់ឡើយ។

២. ត្រូវធានាថាការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗទៀតត្រូវបានអនុវត្តដោយយុត្តិធម៌ និងអស់ពីកម្លាំងចិត្តចំពោះអ្នកភូមិគ្រប់ៗរូប។

៣. ត្រូវប្រកាន់ខ្ជាប់ឥរិយាបថអព្យាក្រឹត ឥតលម្អៀង នៅក្នុងការបំពេញការងារភូមិ និងក្នុងសកម្មភាពរបស់ខ្លួនទាក់ទងនឹងការងារបោះឆ្នោត។

៤. ត្រូវយកចិត្តទុកដាក់ ជាពិសេសធ្វើយ៉ាងណាកុំឱ្យអ្នកភូមិអាចមានការចាប់អារម្មណ៍ថា " **ខ្លួនកំពុងបំពេញភារកិច្ច ដោយលម្អៀងទៅលើគណបក្សណាមួយ** "។

៥. មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ មានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវិតនយោបាយ ដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើសក្នុងឋានៈជាបុគ្គលឯកជន ពេលគឺមិនមែនក្នុងតួនាទីជាមេភូមិ ឬអនុប្រធានភូមិ ឬសមាជិកភូមិឡើយ។

# II-ចៀសវាងការគំរាមកំហែង



មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ពុំមានសិទ្ធិកត់ត្រា ឬសួរអ្នកភូមិ
អំពីគណបក្សនយោបាយ ដែលពួកគាត់បោះឆ្នោតគាំទ្រឡើយ




| **បម្រាម ៖** | |
|---|---|
| ១. | ហាមប្រមូលយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត (ឯ.អ) របស់អ្នកភូមិ ទោះជាដោយសារហេតុផលអ្វីក៏ដោយ ពីព្រោះសកម្មភាពនេះអាចធ្វើឱ្យមានការបកស្រាយថាជាការគំរាមកំហែង ដោយមូលហេតុនយោបាយ។ ប្រជាពលរដ្ឋក៏អាចមានការភ័យខ្លាច ដោយគិតថាអាជ្ញាធរមូលដ្ឋានចង់រារាំងពួកគាត់មិនឱ្យបោះឆ្នោត។ |

២. ហាមរារាំងអ្នកភូមិគ្រប់រូបដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំជាសាធារណៈ ឬរបស់គណបក្សនយោបាយ ឬទទួលព័ត៌មានពីគណបក្សនយោបាយណាមួយ។

៣. ហាមព្យាយាមសួរអ្នកភូមិអំពីគណបក្សនយោបាយដែលពួកគាត់ពេញចិត្ត ឬមិនពេញចិត្ត។

៤. ហាមព្យាយាមផ្តល់ដំបូន្មាន ឬបញ្ចុះបញ្ចូលអ្នកភូមិឱ្យបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ទោះបីជាសកម្មភាពទាំងនេះធ្វើឡើងក្នុងបំណងល្អក៏ដោយ ក៏ច្បាប់ហាមប្រាមទាំងស្រុងដែរ។

៥. ហាមធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយណាមួយ ពីព្រោះឥទ្ធិពលរបស់មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមានទំហំធំធេងណាស់ចំពោះអ្នកភូមិ។ សកម្មភាពបែបនេះអាចត្រូវបានគេចាត់ទុកថាមិនយុត្តិធម៌ចំពោះគណបក្សផ្សេងៗ។

៦. ហាមប្រើពាក្យសម្តីបញ្ជឺតបញ្ជៀង ឬថ្កោលទោសបុគ្គលណាម្នាក់ដោយសារប្រយោជន៍ផ្នែកនយោបាយ ឬផ្ទាល់ខ្លួន។

**ត្រូវព្យាយាមធ្វើឱ្យបាន ៖**

១. គប្បីយល់ឱ្យច្បាស់ថាអ្នកភូមិមានសេរីភាពក្នុងការបញ្ចេញមតិផ្ទាល់របស់ខ្លួនគាត់ ដូច្នេះមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិមិនត្រូវរារាំងគាត់ ដោយសកម្មភាពក្នុងរូបភាពណាមួយឡើយ។

២. ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូបឱ្យបានស្មើគ្នា។ ឧទាហរណ៍៖ នៅពេលមានតម្រូវការស្នើសុំផ្តល់សេវាសាធារណៈផ្សេងៗ ត្រូវយកចិត្តទុកដាក់ផ្តល់សេវាដល់អ្នកភូមិគ្រប់ៗគ្នា ដោយគ្មានការរើសអើង។

៣. ប្រុងប្រយ័ត្ន កុំបង្ហាញឱ្យមានការចាប់អារម្មណ៍ថា មានសកម្មភាព ឬឥរិយាបថកំពុងតែព្យាយាមដោយផ្ទាល់ ឬដោយប្រយោល ដើម្បីគំរាមកំហែង ឬបំភិតបំភ័យអ្នកបោះឆ្នោត ដោយសារតែនិន្នាការនយោបាយខុសៗគ្នាណាមួយរបស់អ្នកភូមិ។

## III-សហការជាមួយនឹងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់



មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវសហការចែក
ឬ/និងផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋដោយពុំមានការរើសអើង

**ត្រូវព្យាយាមធ្វើឱ្យបាន ៖**

១. យកចិត្តទុកដាក់អនុវត្តមុខងារ និងភារកិច្ច ដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវឱ្យធ្វើ ដោយហេតុថាច្បាប់បោះឆ្នោតតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់សហការជាមួយនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព។

២. ជួយជ្រោមជ្រែងមន្ត្រីបោះឆ្នោតដែលត្រូវការជំនួយដើម្បីអនុវត្តការងារបោះឆ្នោតនៅក្នុងឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានទាក់ទងនឹងការងារពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត ការចែកឯកសារនានា ដូចជា ចែកខិត្តបណ្ណ លិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ បណ្ណព័ត៌មានអ្នកបោះឆ្នោត សៀវភៅសម្រាប់អ្នកបោះឆ្នោត និងឯកសារបោះពុម្ពផ្សាយផ្សេងៗទៀត។

៣. ដោយហេតុថាមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ជាមនុស្សសំខាន់ក្នុងការទាក់ទងរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកភូមិ វាជាការចាំបាច់ត្រូវអនុវត្តការងារដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ ដោយមិនត្រូវគិតថ្លៃពីអ្នកភូមិ ឬអ្នកបោះឆ្នោត។

៤. វាជាការចាំបាច់ដែលមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវបំពេញការងាររបស់ខ្លួនតាមមធ្យោបាយច្នៃប្រឌិតណាមួយ ដែលធ្វើឱ្យអ្នកភូមិជឿទុកចិត្តថា **ខ្លួនពិតជាប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងប្រាកដមែន**។

**សំណូមពរ**

១. សូមលោក លោកស្រី បំពេញតួនាទីរបស់ខ្លួនប្រកបដោយភាពប្រាកដប្រជាក្នុងចិត្ត ពីព្រោះលោក លោកស្រីមានសៀវភៅណែនាំនេះ ដែលជួយផ្តល់នូវព័ត៌មានចាំបាច់ និងគោលការណ៍សំខាន់ៗ ក្នុងការអនុវត្តភារកិច្ចដោយជំហរអព្យាក្រឹតឥតលម្អៀង។

២. លោក លោកស្រី គឺជាតំណាងប្រជាពលរដ្ឋក្នុងភូមិទាំងអស់ ដូចនេះសូមលោក លោកស្រី ផ្តល់ព័ត៌មានចាំបាច់នានាទាក់ទងនឹងដំណើរការបោះឆ្នោតដល់អ្នកភូមិគ្រប់រូបឱ្យបានស្មើៗគ្នា។

៣. សូមលោក លោកស្រី ផ្តល់កិច្ចសហការឱ្យបានជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ពិសេសក្នុងដំណើរការចែកបណ្ណព័ត៌មានអ្នកបោះឆ្នោត ដើម្បីធ្វើយ៉ាងណាឱ្យដំណើរការនេះប្រព្រឹត្តទៅបានល្អ មានប្រសិទ្ធភាព និងបានដល់ប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោតគ្រប់រូប ដោយមិនប្រកាន់និន្នាការនយោបាយណាមួយឡើយ។

គ.ជ.ប សូមថ្លែងអំណរគុណចំពោះការអនុវត្តទៅតាមកាតព្វកិច្ច និងការទទួលខុសត្រូវរបស់លោក លោកស្រីមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិទាំងអស់ ដែលធ្វើការក្នុងស្មារតីធ្វើឱ្យបរិយាកាសបោះឆ្នោតប្រព្រឹត្តទៅដោយសុខសន្តិភាព សុវត្ថិភាព និងធ្វើឱ្យមានការជឿទុកចិត្តគ្នា និងការគោរពគ្នាទៅវិញទៅមកក្នុងចំណោមប្រជាពលរដ្ឋក្នុងភូមិទាំងអស់។

បោះពុម្ពដោយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឆ្នាំ២០២៣

អាសយដ្ឋាន ៖ អគារទីស្ដីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

Email : info@nec.gov.kh, www.nec.gov.kh, www.voterlist.nec.gov.kh, App NEC KH